# សេចក្តីប្រកាសព័ត៌មាន

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាចាប់ផ្តើមធ្វើយុទ្ធនាការប្រចាំឆ្នាំដើម្បីប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») នឹងចាប់ផ្តើមធ្វើយុទ្ធនាការ ១៦ ថ្ងៃ ប្រចាំឆ្នាំរបស់ខ្លួន ដើម្បីបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។

កាលបរិច្ឆេទសំខាន់នេះជាការប្រារព្ធទិវាអន្តរជាតិដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី។ អំពើហិង្សាលើស្ត្រីនៅតែជាការរំលោភបំពានសិទ្ធិមនុស្សដែលកើតមានដ៏ច្រើន និងបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរក្នុងចំណោមការរំលោភបំពានសិទ្ធិមនុស្សនានានៅលើពិភពលោក ហើយក៏មានផងដែរនៅក្នុងប្រទេសកម្ពុជា។ តាមការប៉ាន់ប្រមាណ ស្ត្រីកម្ពុជាច្រើនជាងម្នាក់ក្នុងចំណោមប្រាំនាក់ធ្លាប់រងការរំលោភបំពានពីសំណាក់ដៃគូរបស់ខ្លួន គេជឿថាតួលេខនេះបានកើនឡើងក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩។ យុទ្ធនាការ ១៦ ថ្ងៃ របស់ ម.ស.ម.ក នឹងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់ស្ត្រី និងផលប៉ះពាល់ដែលបង្កឡើងពីអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងចំណោមសហគមន៍របស់យើង និងអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាឱ្យចាត់វិធានការដាក់លាក់ជាបន្ទាន់ដើម្បីបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ព្រមទាំងលើកកម្ពស់សមភាពយេនឌ័រនៅក្នុងប្រទេស។

យុទ្ធនាការនេះនឹងប្រព្រឹត្តទៅរហូតដល់ទិវាសិទ្ធិមនុស្សអន្តរជាតិ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣ ដែលជាទិវាសំខាន់ក្នុងការប្រារព្ធខួបនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ជាឯកសារគាំទ្រក្របខ័ណ្ឌសិទ្ធិមនុស្សអន្តរជាតិ និងមានបញ្ចូលជាលើកដំបូងនូវសិទ្ធិមនុស្សជាមូលដ្ឋានសម្រាប់មនុស្សគ្រប់រូប។ ប្រធានបទនៃទិវាសិទ្ធិមនុស្សសម្រាប់ឆ្នាំ២០២៣ គឺ «**សេចក្តីថ្លៃថ្នូរ សេរីភាព និងយុត្តិធម៌សម្រាប់ទាំងអស់គ្នា**»។

ក្នុងរយៈពេលនេះ ម.ស.ម.ក ក៏នឹងប្រារព្ធទិវាសំខាន់ៗផ្សេងទៀតនៅលើប្រតិទិនសិទ្ធិមនុស្ស ក្នុងនោះរួមទាំងទិវាអ្នកការពារសិទ្ធិមនុស្សជាស្ត្រីអន្តរជាតិ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ និងទិវាអ្នកការពារសិទ្ធិមនុស្សអន្តរជាតិនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៣ ដែលជាកាលបរិច្ឆេទសំខាន់ក្នុងការរម្លឹកពីការប្តេជ្ញាចិត្ត និងឆន្ទៈមោះមុតរបស់អ្នកការពារសិទ្ធិមនុស្សក្នុងការតស៊ូមតិ ការអប់រំ និងការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្សក្នុងសហគមន៍របស់យើង។

ជារួម ទិវាសំខាន់ទាំងនេះបង្កើតនូវឱកាសសម្រាប់ដៃគូពាក់ព័ន្ធ ជាពិសេស តួអង្គដែលមានកាតព្វកិច្ចក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស ដូចជា រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលជាដើម បញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការការពារ និងការលើកកម្ពស់សិទ្ធិមនុស្ស។

តាមរយៈយុទ្ធនាការនេះ ម.ស.ម.ក នឹងអនុវត្តសកម្មភាពមួយចំនួនជាបន្តបន្ទាប់ដូចខាងក្រោម៖

- នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ជាទិវាអន្តរជាតិដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី និងកុមារ ម.ស.ម.ក នឹងចេញផ្សាយសេចក្តីប្រកាសអញ្ជើញសាធារណជនឱ្យចូលរួមផ្ញើសំណួរទាក់ទងនឹងវិធីធ្វើយ៉ាងណាក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រី និងក្មេងស្រីទៅកាន់រាជរដ្ឋាភិបាលកម្ពុជា។

- នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ ជាទិវាអន្តរជាតិសម្រាប់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី ម.ស.ម.ក នឹងចេញផ្សាយវីដេអូខ្លីស្តីពី **សកម្មភាពសាមញ្ញដែលខ្ញុំអាចធ្វើបានដើម្បីគាំទ្រដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី** ដែលលើកឡើងអំពីការងារ និងបញ្ហាដែលអ្នកការពារសិទ្ធិមនុស្សជាស្ត្រីប្រឈមដោយសារភាពសកម្មរបស់ពួកគេ និងថាតើសាធារណជនអាចគាំទ្រពួកគេបានដោយរបៀបណា។
- នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៣ ម.ស.ម.ក នឹងចេញផ្សាយខិត្តប័ណ្ណព័ត៌មានមួយក្នុងគោលបំណងជំរុញឱ្យមានការចាប់អារម្មណ៍លើសិទ្ធិអ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នា ហើយក្នុងនោះក៏មានបញ្ចូលសំណួរសំខាន់ៗចំនួន១០សម្រាប់ដាក់ជូនទៅកាន់រដ្ឋាភិបាលថ្មីទាក់ទងនឹងយុទ្ធសាស្ត្រក្នុងការទប់ស្កាត់ និងលុបបំបាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រផងដែរ។ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣ ម.ស.ម.ក នឹងប្រារព្ធយុទ្ធនាការ ១៦ ថ្ងៃ ជាមួយដៃគូពាក់ព័ន្ធនៅទីលានប្រជាធិបតេយ្យក្នុងរាជធានីភ្នំពេញ។
- នៅថ្ងៃទី០៥ និងទី០៧ ខែធ្នូ ឆ្នាំ២០២៣ ម.ស.ម.ក នឹងចេញផ្សាយរូបភាពមានភ្ជាប់សំណេរបរិយាយអំពីដំណើររឿងរបស់ស្ត្រីដែលជាប់ពន្ធនាគារចំនួនពីរនាក់ ដែលផ្តោតការចាប់អារម្មណ៍លើហេតុការណ៍ដែលបានបណ្តាលឱ្យសកម្មជនម្នាក់ៗជាប់ពន្ធនាគារ។
- នៅព្រឹកថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ម.ស.ម.ក នឹងរៀបចំកម្មវិធីនៅការិយាល័យផ្ទាល់ដើម្បីប្រារព្ធយុទ្ធនាការ ១៦ ដើម្បីបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងទិវាសិទ្ធិមនុស្ស ទន្ទឹមនេះ ម.ស.ម.ក ក៏នឹងរៀបចំកម្មវិធីជាសាធារណៈដើម្បីផ្សព្វផ្សាយ និងចែកជូនឯកសារបោះពុម្ពរបស់ខ្លួនដល់សាធារណជន ព្រមទាំងមានរៀបចំកម្មវិធីកម្សាន្តឆ្លើយសំណួរទាក់ទងនឹងសិទ្ធិមនុស្សដើម្បីទទួលបានរង្វាន់ ក៏ដូចជាការផ្តល់វត្ថុអនុស្សាវរីយ៍ដល់អ្នកចូលរួមដែលឆ្លើយសំណួរត្រឹមត្រូវផងដែរ។
- នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣ ដើម្បីចូលរួមប្រារព្ធទិវាសិទ្ធិមនុស្ស និងបិទបញ្ចប់យុទ្ធនាការនេះ ម.ស.ម.ក នឹងចេញផ្សាយកាលប្បវត្តិស្តីពីសិទ្ធិមនុស្សឆ្នាំ២០២៣ ព្រមទាំងកម្រងឯកសារលើកឡើងនូវទិដ្ឋភាពរួមផ្អែកតាមព្រឹត្តិការណ៍ដែលបានកត់ត្រាសំខាន់ៗ តាមខែនីមួយៗផងដែរ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន យុធ្យា នាយកតស៊ូមតិ ម.ស.ម.ក តាមរយៈទូរស័ព្ទ៖ +៨៥៥ (០) ៨៨ ៨១៤ ២៧៨៣ ឬអ៊ីម៉ែល yuthyia@cchrcambodia.org ឬ លោក លឹម បូរិន អ្នកសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ការបង្ហាញទំនោយេនឌ័រ និងលក្ខណៈភេទ ម.ស.ម.ក តាមរយៈទូរស័ព្ទ: + ៨៥៥ (០) ១២ ៩០៤ ២៦៦ ឬ អ៊ីម៉ែល: borin.lim@cchrcambodia.org ។

-ចប់-

**<u>បណ្ណាធិការ៖</u>**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ទនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) បណ្តាញសកលដើម្បីសេរីភាពខាងការបញ្ចេញមតិ និងសម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ (CIVICUS) ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិក OECD-Watch ជាសមាជិកនៃបណ្តាញប្រឆាំងទារុណកម្ម អែស អូ អែស និងសម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងជាជ័យលាភីទទួលពានរង្វាន់ក្នុងឆ្នាំ ២០១៣ ផ្នែកទំនាក់ទំនងដើម្បីផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រ៊ីសបេន ប្រទេសអូស្ត្រាលី ៕